សូមគោរពឪពុកម្តាយ/អ្នកថែទាំ

**ស្តីពី៖ ជំរឿនការអភិវឌ្ឍន៍កុមារតូចអូស្ត្រាលី**

លិខិតនេះ និងខិត្តប័ណ្ណព័ត៌មានដែលភ្ជាប់មកជាមួយ រួមមានព័ត៌មានសំខាន់ៗអំពី ជំរឿនការអភិវឌ្ឍន៍កុមារតូចអូស្ត្រាលី (Australian Early Development Census (AEDC)) និងការដាក់ស្នើគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួនរបស់កូន/កូនៗអ្នក។

សាលារៀនរបស់យើងនឹងចូលរួមក្នុង AEDC រវាងខែឧសភា និងខែកក្កដាឆ្នាំនេះ។ AEDC គឺជាជំរឿនថ្នាក់ជាតិដែលធ្វើឡើងរៀងរាល់បីឆ្នាំម្តង ដោយរដ្ឋាភិបាលអូស្ត្រាលី ដោយសហការជាមួយរដ្ឋាភិបាលថ្នាក់រដ្ឋ និងដែនដី។ វាវាស់ស្ទង់ពីរបៀបដែលកុមារបានអភិវឌ្ឍ មកទល់នឹងពេលដែលពួកគេចាប់ផ្តើមចូលរៀនពេញម៉ោងឆ្នាំនៅដំបូង។

AEDC គឺជាការស្ម័គ្រចិត្ត ហើយវាមិនវាស់ស្ទង់ពីរបៀបដែលកុមារធ្វើកិច្ចការបានល្អនៅសាលារៀន ឬថាសាលារៀនរបស់ពួកគេប្រៀបធៀបដូចម្តេចដែរទៅនឹងសាលារៀនផ្សេងទៀតនោះទេ។ ផ្ទុយទៅវិញ វាបង្ហាញពីរបៀបដែលកុមារកំពុងលូតលាស់ និងរីកចម្រើននៅក្នុងវិស័យសំខាន់ៗចំនួនប្រាំ អ្វីដែលកំពុងធ្វើបានល្អ ហើយនិងអ្វីដែលអាចត្រូវបានកែលម្អ។ ទិន្នន័យ AEDC ត្រូវបានប្រើប្រាស់ដោយសាលារៀន អង្គការកុមារតូច អ្នកស្រាវជ្រាវ និងរដ្ឋាភិបាលដើម្បីជួយរៀបចំផែនការ និងកែលម្អសេវាកម្ម និងការគាំទ្រនានាសម្រាប់កុមារ និងគ្រួសារ។ នេះហើយជាមូលហេតុដែលវាមានសារៈសំខាន់ សម្រាប់កុមារទាំងអស់នៅក្នុងឆ្នាំសិក្សាដំបូងរបស់ពួកគេដែលត្រូវដាក់បញ្ចូលក្នុង AEDC។ អ្នកអាចស្វែងយល់បន្ថែមអំពីវិធីដែលទិន្នន័យ AEDC ត្រូវបានប្រើប្រាស់នៅតាមគេហទំព័រ https://www.aedc.gov.au/

**តើនេះមានន័យដូចម្តេចដែរចំពោះកូនរបស់អ្នក?**

AEDC ត្រូវបានបំពេញដោយគ្រូដោយផ្អែកលើចំណេះដឹងរបស់ពួកគេអំពីកុមារ។ កុមារមិនចាំបាច់ធ្វើអ្វីដើម្បីដាក់បញ្ចូលក្នុងជំរឿនទេ ហើយនឹងចូលថ្នាក់រៀនដូចធម្មតា ខណៈពេលដែលជំរឿនកំពុងត្រូវបានធ្វើឡើង។

ជំរឿននឹងចាប់ផ្តើមតាមកាលបរិច្ឆេទដូចខាងក្រោម៖ ________________

គ្រូនឹងឆ្លើយសំណួរនានាអំពីវិស័យសំខាន់ៗចំនួនប្រាំនៃការអភិវឌ្ឍន៍កុមារតូចគឺ៖ សុខភាពរាងកាយ និងសុខុមាលភាព ភាពចាស់ទុំខាងអារម្មណ៍ សមត្ថភាពសង្គម ជំនាញភាសា និងការយល់ដឹង (ផ្អែកលើសាលា) និងជំនាញទំនាក់ទំនង ហើយនិងចំណេះដឹងទូទៅ។ អ្នកអាចមើលសំណួរទាំងអស់នៅតាមគេហទំព័រ https://www.aedc.gov.au/avedi

**អ្នកអាចជឿជាក់ថាឯកជនភាពរបស់កូនអ្នកនឹងត្រូវបានការពារ។**

យើងយល់ដឹងពីសារៈសំខាន់នៃការរក្សាព័ត៌មានរបស់កូនអ្នកជាលក្ខណៈឯកជន។ នេះហើយជាមូលហេតុដែល AEDC ប្រើប្រាស់គេហទំព័រសុវត្ថិភាពដើម្បីប្រមូល និងរក្សាទុកព័ត៌មានរបស់ពួកគេ។

ព័ត៌មានបន្ថែមអំពីរបៀបដែលទិន្នន័យ AEDC (រួមទាំងព័ត៌មានរបស់កូនអ្នក) ត្រូវបានប្រមូល ការពារ និងប្រើប្រាស់ មានចែងនៅក្នុងខិត្តប័ណ្ណព័ត៌មាន។

**តើឪពុកម្តាយចាំបាច់ត្រូវធ្វើអ្វីខ្លះ?**

សម្រាប់គោលបំណងនៃ AEDC ក្រសួងអប់រំរបស់រដ្ឋាភិបាលអូស្ត្រាលី ស្វែងរកការយល់ព្រមរបស់អ្នកដើម្បីប្រមូលព័ត៌មានផ្ទាល់ខ្លួនអំពីកូនរបស់អ្នកពីសាលារៀនរបស់យើង។ នេះរួមបញ្ចូលទាំងព័ត៌មានដែលបានដឹងអំពីសុខភាពកូនរបស់អ្នក។

ប្រសិនបើអ្នកយល់ព្រមចំពោះការប្រមូលព័ត៌មានរបស់កូនអ្នក អ្នកមិនចាំបាច់ធ្វើអ្វីនោះទេ។

ប្រសិនបើអ្នកមិនយល់ព្រមចំពោះការប្រមូលព័ត៌មានរបស់កូនអ្នកទេ សូមទាក់ទងអ្នកដែលបានរាយឈ្មោះខាងក្រោម ឱ្យបានមុនកាលបរិច្ឆេទដូចបង្ហាញខាងក្រោម ហើយគ្មានព័ត៌មានអំពីកូនរបស់អ្នកនឹងត្រូវបានប្រមូលទេ៖

ឈ្មោះអ្នកទំនាក់ទំនង ________________

ព័ត៌មានទំនាក់ទំនងលម្អិត សម្រាប់អ្នកទំនាក់ទំនងនៅសាលារៀន ________________

កាលបរិច្ឆេទចុងក្រោយ ដើម្បីទាក់ទងមកអ្នកទំនាក់ទំនងនៅសាលារៀន ដើម្បីជ្រើសរើសមិនចូលរួម ________________

អ្នកក៏អាចដកការយល់ព្រមរបស់អ្នកបន្ទាប់ពីពេលនេះផងដែរ។ ប្រសិនបើអ្នកធ្វើដូច្នេះ ក្រសួងអប់រំរបស់រដ្ឋាភិបាលអូស្ត្រាលីនឹងឈប់ប្រើប្រាស់ព័ត៌មានរបស់កូនអ្នក ហើយនឹងមិនផ្តល់ព័ត៌មាននេះដល់នរណាម្នាក់ផ្សេងទៀតឡើយ។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានដែលបានចែករំលែក ធ្វើរបាយការណ៍ ឬបោះពុម្ពរួចហើយនោះ មិនអាចដកចេញបានទេ ហើយអាចបន្តប្រើប្រាស់ (ប៉ុន្តែកូនរបស់អ្នកនឹងមិនត្រូវបានកំណត់អត្តសញ្ញាណដោយផ្ទាល់នៅក្នុងព័ត៌មាននោះទេ)។

ដើម្បីស្វែងយល់បន្ថែមអំពី AEDC សូមអានផ្នែកសំណួរដែលគេសួរញឹកញាប់នៅលើគេហទំព័រ AEDC នៅតាមគេហទំព័រ https://www.aedc.gov.au/parents/faq-for-parents ឬទូរសព្ទ 1800 092 548។

ព័ត៌មានរបស់កូនអ្នកនឹងត្រូវបានប្រើសម្រាប់តែគោលបំណងដែលបានពិពណ៌នានៅក្នុងលិខិតនេះ និងក្នុងខិត្តប័ណ្ណព័ត៌មានប៉ុណ្ណោះ។ សេចក្តីថ្លែងស្តីពីសិទ្ធិឯកជនដែលមាននៅលើគេហទំព័រ AEDC ផ្តល់ព័ត៌មានលម្អិតបន្ថែមអំពីរបៀបដែលព័ត៌មានរបស់ពួកគេនឹងត្រូវបានការពារ និងចែករំលែក ហើយអាចរកបាននៅតាមគេហទំព័រ៖ www.aedc.gov.au/parents/privacy-statement

សូមអរគុណអ្នកចំពោះការគាំទ្រ AEDC។

នាយកសាលា

**សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ**

ប្រសិនបើអ្នកត្រូវការជំនួយអ្នកបកប្រែផ្ទាល់មាត់ដើម្បីទាក់ទងមកសាលារៀន សូមហៅទូរសព្ទលេខ 131 450 ប្រាប់ការីទូរសព្ទនូវភាសាដែលអ្នកត្រូវការ ហើយស្នើសុំឱ្យពួកគេទូរសព្ទទៅសាលារៀន។ ការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ ដើម្បីជួយក្នុងការសន្ទនារបស់អ្នក។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។